ជស/រកម/០១៩៨/០១

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * * * * * * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស.៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៥.៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.០៨៩៧.១៨៧ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងរបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៣១ ខែ[illegible] ឆ្នាំ១៩៩៨ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

## ស្តីពីចំណូល ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

---

---

---

## ជំពូកទី ៥

## បទប្បញ្ញត្តិស្តីពីពន្ធនិងអាករ

**មាត្រា ១៣.**

ច្បាប់ស្តីពីសារពើពន្ធដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស. រកម ០២៩៧.០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោមនេះ :

-មាត្រា ៥៥ ត្រូវបានកែប្រែដូចតទៅ " ថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៩៩ នឹងត្រូវបានបង្កើតអាករលើតម្លៃបន្ថែមចំពោះការផ្គត់ផ្គង់ជាប់អាករ ដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋ ។ "

-ពាក្យ "ថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៩៨" ក្នុងកថាខ័ណ្ឌ ៥ នៃមាត្រា ៨៦ ត្រូវបានកែប្រែដូចតទៅ :" ថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៩៩ ។"

**មាត្រា ១៤.**

ចំនួនប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទដែលបានកំណត់ក្នុងមាត្រា ៥៣ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ត្រូវបានកំណត់ជាថ្មីដូចមានចែងក្នុងតារាង"ង" ភ្ជាប់ជាមួយនឹងច្បាប់នេះ ។

---

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ១៦.~** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.~** ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៨

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ហត្ថលេខា | ហត្ថលេខា |
| អ៊ុង ហួត | ហ៊ុន សែន |

បានជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទិតិសម្បទាន និង

អភិវឌ្ឍន៍ និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ : ១១ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៨

អគ្គលេខាធិការរាជរដ្ឋាភិបាល

ហត្ថលេខា និង ត្រា

ណា ឌី តាន់